# សិលាចារឹកប្រាសាទបន្ទាយព្រាវ K.២២១ មេទ្វារខាងត្បូង

## ១- ព័ត៌មានទូទៅ

ប្រាសាទបន្ទាយព្រាវ មានទីតាំងស្ថិតនៅភូមិថ្មី ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ អ្នកស្រុកក្នុងតំបន់ហៅថា «ប្រាសាទបន្ទាយព្រាវ» «ប្រាសាទកំផែងព្រាវ» ឬ «ប្រាសាទព្រាវ»។ ប្រាសាទនេះបែរមុខទៅទិសខាងកើត សង់ពីឥដ្ឋ ថ្មបាយក្រៀម និងថ្មភក់។ នៅខាងកើតប្រាសាទបន្ទាយព្រាវ មានបារាយណ៍ធំមួយ បណ្ដោយកើតលិចប្រមាណ៤០០ម៉ែត្រ និងទទឹងជើងត្បូងប្រមាណ២៥០ម៉ែត្រ[១]។ កំពែងជាន់ទីមួយ មានប្រវែងកើតលិចប្រវែង១៦០ម៉ែត្រ ជើងត្បូង១២០ម៉ែត្រ[២] មានគូទឹក និងផ្លូវចូលប្រាសាទ។ នៅកំពែងជាន់ទីពីរ មានកំពែងថ្មមួយខណ្ឌកាត់ទទឹងហើយចែកទីធ្លាប្រាសាទជាពីរ។ នៅធ្លាទីមួយប្រទះឃើញបំណែកបដិមាគោនន្ទីមួយ។ ធ្លាទីពីរ មានប្រាសាទបី ដែលតាមរយៈសិលាចារឹកចារលើមេទ្វារនៃប្រាសាទនីមួយៗ បានឱ្យដឹងថាប្រាសាទកណ្ដាលជាប្រាសាទសិវលិង្គ ប្រាសាទខាងត្បូងតម្កល់ព្រះឥសូរព្រះនាមបរមេសូរ ប្រាសាទខាងជើងតម្កល់ព្រះភគវតីព្រះឥសូរ គឺនាងឧមា។ ដូច្នេះ ប្រាសាទបន្ទាយព្រាវជាប្រាសាទឧទ្ទិសដល់ទេពនិកាយព្រះឥសូរ។

សិលាចារឹកនៅប្រាសាទនេះ មានចំនួនប្រាំ។ សិលាចារឹកលេខ K.២២០ ស្ថិតនៅលើមេទ្វារជើងត្បូងនៃតួប្រាសាទខាងជើង, K.២២១ នៅលើមេទ្វារជើងត្បូងនៃតួប្រាសាទកណ្ដាល, និង K.២២២ នៅលើមេទ្វារតួប្រាសាទខាងត្បូង។ ទាំងបីសិលាចារឹកនេះ សព្វថ្ងៃបានបាត់ពីទីតាំងប្រាសាទនេះទៅហើយ។ សិលាចារឹកមួយផ្ទាំងទៀត K.១២៣៣[៣] ត្រូវ

[១] ទិន្នន័យវាស់ដោយ Google Earth។

[២] លោក អែម៉ូនីញេរ៍, ១៩០១។

[៣] សូមអាន៖ https://ams.com.kh/khmercivilization/detail/8119 និងទស្សនាវដ្ដីកម្ពុជសុរិយា លេខ៤, ២០២០ ទំព័រ៧៨-១០០។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ប្រជាជនយកចេញពីប្រាសាទតាំងពីឆ្នាំ១៩៩៧ម៉្លេះ ក្រោយមកយកទៅរក្សាទុកនៅសារមន្ទីរខេត្តបន្ទាយមានជ័យនៅឆ្នាំ២០១៩[៤]។ សិលាចារឹកមួយទៀតដឹកចេញពីប្រាសាទនៅឆ្នាំ១៩៩៩ ដែលបច្ចុប្បន្ននៅសារមន្ទីរស្រុកស្វាយចេកជាសិលាចារឹកមិនទាន់ចុះលេខក្នុងបញ្ជីសារពើភណ្ឌនៅឡើយទេ។ សិលាចារឹក K.២២១ មេទ្វារខាងត្បូង ដែលលើកយកមកសិក្សាក្នុងអត្ថបទនេះចារនៅលើមេទ្វារថ្មភក់ពណ៌ផ្កាឈូក មានចំនួន១១បន្ទាត់ ជាភាសាខ្មែរបុរាណ។

កន្លងមក ធ្លាប់មានអ្នកលើកយកអត្ថបទចារឹកនេះ មកសិក្សារួចហើយ ដូចជានៅឆ្នាំ១៩៥១ លោកសាស្ត្រាចារ្យ ហ្សឺក សេដេស បានសិក្សាអត្ថចារឹកនេះ រួមនិងK.២២២ក្នុងសៀវភៅ «សិលាចារឹកនៃប្រទេសកម្ពុជា» ក្បាលទី៣។ លោកសាស្ត្រាចារ្យ ហ្វីលីព ចេណ្ណឺរ បានសិក្សាអត្ថបទនេះក្នុងស្នាដៃលោក Part xml, № 29 និងចេញផ្សាយលើគេហទំព័រ http://sealang.net/ok/corpus.htm[៥] ។

សិលាចារឹកនេះ មានចុះកាលបរិច្ឆេទចំនួន៣ គឺនៅមហាសករាជឆ្នាំ៩២៩ (គ.ស. ១០០៧), ឆ្នាំ៩៣០ (គ.ស. ១០០៨), និងឆ្នាំ៩៣៣ (គ.ស. ១០១១)។ នៅម.ស.៩២៩ វាបអម្រឹតបានថ្វាយដីដល់ព្រះគម្តែងអញសិវលិង្គនៅត្បូងរមាំង (ត្រូវនឹងប្រាសាទបន្ទាយព្រាវ)[៦] ដោយមានមេទ័ព និងចៅហ្វាយខេត្ត ទៅសង់គោលព្រំដី។ នៅឆ្នាំដដែលនេះវាបអ្យកបានថ្វាយដីដល់ប្រាសាទ និងមានមន្ត្រីទៅសង់គោល។ នៅម.ស.៩៣០ ម្រតាញទ្រីបេន្ទ្រវល្លភៈ បានថ្វាយដីដល់ប្រាសាទដោយមានមន្ត្រីជាសាក្សី។ ចុងក្រោយនៅម.ស. ៩៣៣ មានមន្ត្រីច្រើននាក់រួមគ្នាលក់ស្រែថ្កូលជង/ជង់ឱ្យកំស្តែងស្រីនរបតីន្ទ្រវម៌្ម ក្នុងតម្លៃប្រាក់ស១០តម្លឹង និងមានមន្ត្រីទៅសង់គោល។

[៤] លោក ហ៊ិន ឈុនតេង, ២០២០។

[៥] សូមជ្រើសយកលេខ «K.221S»។

[៦] សូមអានបន្ថែមទាក់ទងនឹងស្ថាននាម «ត្បូងរមាំង»៖ https://ams.com.kh/khmercivilization/detail/8695។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

## ២- អត្ថបទដើមជាភាសាខ្មែរទំនើប

(១)- ៩២៩គកបិកេតជេម្នអង្គាររវារនុវាបិអម្ពូតស្មេរបញ្ចគ្រាមឱយិភូមិតវ្រះកម្រតេងអញ
គិវលិង្គប្ឆ្វងម្នាងិត

(២)- សង្កោលិខ្ញោញិវលខ្ញោញិវិមយអ្មោយបុរស្រុកិករណិ[៧]ខ្ញោញិវលខ្ញោញិសំតាបិជ្រៃ
វលី។៩២៩គកបញ្ចមីកេ

(៣)- តិជេម្នវ្រហស្បតិវារនុវាបិអ្យកិស្រុកិប្រលាយិផ្ទុំឯកិឱយិភូមិតវ្រះកម្រ(តេងអញ)គិវ
លិង្គតសង្កោលិខ្ញោញិវលខ្ញោ

(៤)- ញិវិមយខ្ញោញិវ(លខ្ញោញិ)សំតាបិជ្រៃវលី។(៩៣០)គកអប្តមីរោចិជេម្នអាទិត្យវា(រនុ)
ម្រ(តាញិគ្រីន្ទ្វ)បេន្ទ្រវល្ពស្រុកិជ្រៃគ

(៥)- យ៉្យាកិឱយិ(ស្រេអាចា)យ៉្យទ្រោណតម្ទិម្រ(តាញិបិ)កល្បនាជាស្រេចុរវិតវ្រះកម្រតេ
ងអញិគិវលិង្គតជាសាក្សិយ

(៦)- ខ្ញោញិវលករណិខ្ញោញិវិមយខ្ញោញិវលស្តុកិទង្ផោងអធ្យាបកអាយិកន្ទោងកំម្រតេង
អញិរាជគុហាវាបិសានិសំពោង

(៧)- យ្វាតិ។៩៣៣គកបញ្ចមិ[៨]កេតិមាឃសនៃគ្នុវារនុវាបអាខ្ញោញិវ្រិហ[៩]វាបិធម៌្មប្រជា
នវាបិវម៌្មគិវកម្មានត្តស្រុកិថ្វាលិ

(៨)- ជោងយុគ(បតិ)[១០]នុម្រតាញិខ្ញោញិគ្រិរាជេន្ទ្របន្ទិតស្រុកិយនបិស្តេងភវក្សេត្រខ្ញោ
ញិសំតាបិនុម្រតាញិគ្រិគ្រុតភក្តិវិខ្យាតព្ទ

(៩)- ស្រុកិជ្រៃវលីស្តេងភគវនិកន្ទោងកម្រតេងអញិរាជគុហាលោញិនោសិប្រលាយិ
លោញិមាធវចុងស្រុកិខ្ញោញិវលយាំបះ

---

[៧] លោក សេដេស និងលោក ចេណ្ណឹរ អានជា «ករណី»។

[៨] លោក សេដេស និងលោក ចេណ្ណឹរ អានជា «បញ្ចមី»។

[៩] លោក សេដេស និងលោក ចេណ្ណឹរ អានជា «វ្រីហ»។

[១០] លោក សេដេស និងលោក ចេណ្ណឹរ អានជា «យុគបាទ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

(១០)- ម្រតាញគ្រីសមរវិក្រមស្រុកជ្បុកលោញ--ខ្ញោញផ្ទាលវនិកស្តេញវម្ម៌គិរក(ន្ទ្យង)លោញរាម·បិលកស្រេថ្កាលដោងតកំស្តេង

(១១)- គ្រិនរបតិន្ទ្រវម្ម៌តសង្តោលខ្ញោញវលខ្ញោញរិមយស្រុកករណិថ្វាយស្រេនោះប្រាកលិង១០អេ្យា៎ះ

### ៣- អត្ថបទប្រែសម្រួល

(១-២) មហាសករាជ៩២៩ ទីបីកើត ខែជេស្ឋ ថ្ងៃអង្គារ នូវវាបអម្រឹត(ដែលជា)អ្នកបម្រើការ(នៅ)ភូមិទាំងប្រាំ ថ្វាយដីដល់ព្រះគម្តែងអញសិវលិង្គ(នៅ)ត្បូងរមាំង។ អ្នកសង់គោល(មាន)ខ្ញោញពល ខ្ញោញវិស័យអមោឃបូរ(និង)ស្រុកករណី ខ្ញោញពល (និង)ខ្ញោញសណ្តាប់(នៅ)ជ្រៃវលី។

(២-៤) មហាសករាជ៩២៩ទី ប្រាំកើត ខែជេស្ឋ ថ្ងៃព្រហស្បតិ៍ នូវវាបអ្យក(នៅ)ស្រុកប្រឡាយជាអ្នកធ្វើការនៅព្រះក្រឡាបន្ទំថ្នាក់ទី១ ថ្វាយដីដល់ព្រះគម្តែងអញសិវលិង្គ។ អ្នកសង់គោល(មាន)ខ្ញោញពល ខ្ញោញវិស័យ ខ្ញោញពល ខ្ញោញសណ្តាប់(នៅ)ជ្រៃវលី។

(៤-៧) មហាសករាជ៩៣០ ទីប្រាំបីរោច ខែជេស្ឋ ថ្ងៃអាទិត្យ នូវម្រតាញស្រីទ្រឹបេន្ទ្រវល្លភ(នៅ)ស្រុកជ្រៃគ្រៀក ថ្វាយស្រែ(របស់)អាចារ្យទ្រោណ(ដែលជា)ជីតា(របស់)ម្រតាញគប្បីរៀបចំជាស្រែ(សម្រាប់ធ្វើ)ចរុដល់ព្រះគម្តែងអញសិវលិង្គ។ អ្នកដែលជាសាក្សី(មាន)ខ្ញោញពលករណី ខ្ញោញវិស័យ ខ្ញោញពលស្តុកទង្វោង អធ្យាបកនៅឯកន្ទោងគម្តែងអញរាជគុហា (គឺប្រាសាទភ្នំកង្វា) វាបសាន(នៅ)សំរោងយួត។

(៧-១១) មហាសករាជ៩៣៣ ទីប្រាំកើត ខែមាឃ ថ្ងៃសៅរ៍ នូវវាបអា(ដែលជា)ខ្ញោញស្រូវ វាបធម្ម៌(ដែលជា)ប្រធាន វាបវម្ម៌សិវ(ដែលជា)កម្ម៌ាន្តរ(នៅ)ស្រុកថ្កូលជង ចូលរួមនឹងម្រតាញខ្ញោញស្រីរាជេន្ទ្របណ្ឌិត(នៅ)ស្រុកយនប ស្តេងភវក្សេត្រ(ជា)ខ្ញោញសណ្តាប់ម្រតាញស្រីស្រុតកក្តិវិខ្យាត(នៅ)ស្រុកជ្រៃវលី ស្តែងភគវ័ន(នៅ)កន្ទោងគម្តែងអញរាជគុហា លោញនោស(នៅស្រុក?)ប្រឡាយ លោញមាធវ(នៅ)ចុងស្រុក(ដែលជា)ខ្ញោញពល

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

(នៅ)យាំបះ ម្រតាញស្រីសមរវិក្រម(នៅ)ស្រុកជ្យក លោញ--(ជា)ខ្លោញឈ្នួលនិងឈ្មួញ ស្តេញវម្ម៌សិវក្មេង (និង)លោញរាម គប្បីលក់ស្រែថ្លូលជងដល់កំស្តែងស្រីនរបតីន្ទ្រវម្ម៌។ អ្នកសង់គោល(មាន)ខ្លោញពល (និង)ខ្លោញវិស័យស្រុកករណី ។ ថ្ងៃស្រែនោះ(គឺ)ប្រាក់ស ១០តម្លឹង។

## ៤- ពន្យល់ពាក្យ

| | |
|---|---|
| **ស្មេវ** | < សេវ (សំ.) "សេវា" + [-មិ-]= អ្នកបម្រើការ។ |
| **ខ្លោញ៑វល** | ខ្លោញ៑ < [ក៑-]+លោញ៑ "មេ, ធំ, ប្រធាន" ពាក្យនេះក្លាយជាពាក្យបច្ចុប្បន្នថា ខ្លាង, វល "ពល, ទ័ព"= មេទ័ព។ |
| **ខ្លោញ៑វិមយ** | វិមយ = វិស័យ ជាតំបន់ដែលមានទំហំប្រហាក់ប្រហែលនឹងខេត្តសព្វថ្ងៃដែរ។ ខ្លោញវិស័យ គឺប្រធានគ្រប់គ្រងវិស័យឬចៅហ្វាយខេត្ត។ |
| **ខ្លោញ៑សំតាប៑** | ខ្លោញសណ្តាប់។ |
| **កល្បនា** | ចាត់ចែង, រៀបចំ, អ្វីៗដែលគេរៀបចំ (តង្វាយ)។ |
| **ចុរុ** | (សំ. ចរុ) ចរុ, អាហារជាតង្វាយដល់ព្រះឥសូរ។ |
| **អធ្យាបក** | (សំ.) គ្រូបង្រៀនចំណេះដឹងខាងសាសនា ពិសេសគឺគម្ពីរវេទ។ តាមន័យដើម អធ្យាបក ជាអ្នកនាំឱ្យសិស្សផ្តោតយកចិត្តទុកដាក់លើអ្វីមួយ។ |
| **កន្ទោង៑** | < [កនិ-] + លោង៑ "មេ, ធំ, ប្រធាន" សំដៅដល់ម្តាយ អគារ ឬប្រាសាទ។ ពាក្យនេះក្លាយមកបច្ចុប្បន្នជា **កន្ទោង** និង **កន្ទុង**។ សព្វថ្ងៃមានពាក្យហៅម្តាយថា **កន្ទោង** ឬ **ព្រះកន្ទោង** និងសសរកណ្តាលថា **សសរកន្ទោង**។ |

អត្ថបទដោយៈ ហ៊ុន ឈុនតេង

**ខ្លោញ៑ព្រិហ** ខ្លោញស្រូវ, ប្រធានយកពន្ធផ្នែកស្រូវ។

**កម្មាន្តរ** (សំ.) អ្នករៀបចំបុណ្យសពរបស់ព្រះរាជវង្ស។

**យុគបតិ** < (សំ.) យុគ "រួម, ផ្សំ" + បទ៑ "ជើង, ដំណើរ, ទំនង"= ធ្វើព្រមគ្នា, ចូលរួម។

**ខ្លោញ៑ផ្លាលិ** ខ្លោញឈ្នួល, ប្រធានគ្រប់គ្រងកម្មករឈ្នួល (?)។

**វនិក៑** (សំ. វាណិជ) ពាណិជ្ជករ, ពាណិជ្ជកម្ម។

**អ្យោ** ស។

## ឯកសារយោង


ហ៊ុន ឈុនតេង. ២០២០. សិលាចារឹកថ្មីមកពីប្រាសាទបន្ទាយព្រាវ K.១៤៣៣, កម្ពុជសុរិយា លេខ២៤

ហ៊ុន ឈុនតេង. ២០២១. សិលាចារឹកថ្មីមកពីប្រាសាទបន្ទាយព្រាវ K.១៤៣៣, https://ams.com.kh/khmercivilization/detail/8119

ហ៊ុន ឈុនតេង. ២០២១. ស្ថាននាម «ត្បូងរមាំង» តាមរយៈសិលាចារឹក, https://ams.com.kh/khmercivilization/detail/8695

Aymonier, É. 1901. Le Cambodge, II.

Cœdès, G. 1951. Inscriptions de Bantãy Prãv (K. 220-222) in *Inscriptions du Cambodge*, Vol. 3. Paris.

Jenner, P. Inscription of Bantãy Prãv in *Part xml, № 29*. http://sealang.net/ok/corpus.htm


អត្ថបទដោយ៖ ហ៊ុន ឈុនតេង

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

## បញ្ជីរូបភាព




ប្រាសាទបន្ទាយព្រាវមើលពីលើអាកាស



បារាយណ៍ប្រាសាទបន្ទាយព្រាវ



បំណែកគោនន្ទី



កំពែងថ្មបាយក្រៀមខាងក្រៅ



កំពែងថ្មបាយក្រៀមខាងក្នុង

អត្ថបទដោយៈ ហ៊ុន ឈុនតេង



វត្ថុសិល្បៈជាគ្រឿងលម្អប្រាសាទ



សំណៅផ្ដិតសិលាចារឹកប្រាសាទបន្ទាយព្រាវ K.២២១ ត្បូង

អត្ថបទដោយ៖ ហ៊ុន ឈុនតេង